**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ឧបទ្ទវហេតុអគ្គិភ័យ នៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ដាលី ហ្គាម៉ិន អ៊ីនធើណេសិនណាល (ខេមបូឌា) លីមីធីត
# (DALI GARMENT INTERNATIONAL CAMBODIA LIMITED)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិត និងសាធារណជន ឱ្យបានជ្រាបថា នៅវេលាម៉ោង ១២:០០នាទីរំលងអធ្រាត្រឈានចូលថ្ងៃពុធ ទី២២ ខែឧសភា ឆ្នាំ២០២៤ មានករណីអគ្គិភ័យឆាបឆេះអគារ១ នៃរោងចក្រកាត់ដេរសម្លៀកបំពាក់ ដាលី ហ្គាម៉ិន អ៊ីនធើណេសិនណាល (ខេមបូឌា) លីមីធីត (DALI GARMENT INTERNATIONAL CAMBODIA LIMITED) ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ក្នុងភូមិកែវឧត្តម ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ តែពុំបណ្តាលឱ្យកម្មករនិយោជិតណាម្នាក់រងគ្រោះថ្នាក់ឡើយ។

យោងតាមអាជ្ញាធរមានសមត្ថកិច្ច អគ្គិភ័យនេះអាចបណ្តាលមកពីការឆ្លងចរន្តអគ្គិសនី។ បន្ទាប់ពីទទួលបានព័ត៌មាននេះភ្លាម ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួង បានចុះទៅដល់កន្លែងកើតហេតុ និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងកម្លាំងជំនាញពន្លត់អគ្គិភ័យ ដោយបានពន្លត់ និងគ្រប់គ្រងអគ្គិភ័យបានទាំងស្រុងនៅត្រឹមវេលាម៉ោង ២:៣០នាទី និងមិនបណ្តាលឱ្យរាលដាលទៅកាន់ទីតាំងរោងចក្រផ្សេងទៀតនៅក្បែរនោះឡើយ។

នៅព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នេះ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួង បានបន្តចុះពិនិត្យស្ថានភាពខូចខាតរបស់រោងចក្រ និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ថៅកែ និងរដ្ឋបាលរោងចក្រ ដើម្បីការពារអត្ថប្រយោជន៍ផ្សេងៗរបស់បងប្អូនកម្មករនិយោជិត។ ជាមួយគ្នានេះ ក្រសួងសូមថ្លែងអំណរគុណចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងរដ្ឋបាលខេត្ត ដែលបានសហការក្នុងការពន្លត់អគ្គិភ័យនេះបានទាន់ពេលវេលា។

ទោះបីមានអគ្គិភ័យបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរក៏ដោយ រោងចក្រនៅតែបន្តបើកអាជីវកម្មដំណើរការជាធម្មតា បងប្អូនកម្មករនិយោជិតរោងចក្រនៅតែមានការងារធ្វើ ហើយរោងចក្រនឹងរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗរបស់បងប្អូនកម្មករនិយោជិតដដែល។ ទន្ទឹមគ្នានេះ ការបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នឹងបើកជាធម្មតា សូមបងប្អូនកម្មករនិយោជិតរក្សាជំហរនឹងន និងខិតខំបំពេញការងារដូចសព្វមួយដង។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិត និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩